## គោលបំណងរបស់ CCCA

កម្មវិធី CCCA ត្រូវបានបង្កើតឡើងមានភាពបត់បែន និងច្នៃប្រឌិតសម្រាប់ដោះស្រាយ និងឆ្លើយតបទៅនឹងបញ្ហាប្រែប្រួលអាកាសធាតុ និងការប្រឈមមហានិភ័យគ្រោះមហន្តរាយក្នុងប្រទេសកម្ពុជា ជាលក្ខណៈប្រព័ន្ធ និងប្រកបដោយប្រសិទ្ធិភាព។ គោលបំណងរួមរបស់ CCCA គឺពង្រឹងសមត្ថភាពរបស់ គ.ជ.គ.អ.ប. ដើម្បីអនុវត្តភារកិច្ចរបស់ខ្លួនក្នុងការដោះស្រាយបញ្ហាប្រែប្រួលអាកាសធាតុ និងអាចឱ្យក្រសួងពាក់ព័ន្ធ និងអង្គការសង្គមស៊ីវិលអនុវត្តសកម្មភាពចម្បងៗពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុ។



ការពិភាក្សាក្នុងក្រុមគោលដៅ ដើម្បីសិក្សាប៉ាន់ប្រមាណពីតម្រូវការប្រើប្រាស់ផល អនុផលព្រៃឈើ (ថតដោយគម្រោង CFO ឆ្នាំ ២០១២ ទទួលមូលនិធិពី CCCA វគ្គទី ១)

## សមិទ្ធិផលចម្បងៗ ដែលសម្រេចបាន

- ◊ ដាក់ឱ្យប្រើប្រាស់ជាផ្លូវការនូវផែនការយុទ្ធសាស្ត្រប្រែប្រួលអាកាសធាតុកម្ពុជា ឆ្នាំ២០១៤-២០២៣
- ◊ ក្រសួងពាក់ព័ន្ធបានបញ្ចប់ការរៀបចំផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុតាមវិស័យ និងកំពុងរៀបចំផែនការសកម្មភាពតាមវិស័យរបស់ខ្លួន
- ◊ ពង្រឹងសមត្ថភាពចរចារបស់កម្ពុជា លើបញ្ហាប្រែប្រួលអាកាសធាតុទាំងនៅថ្នាក់ជាតិ និងលើឆាកអន្តរជាតិ
- ◊ បង្កើតវេទិកាចំណេះដឹង និងព័ត៌មានតាមរយៈគេហទំព័ររបស់នាយកដ្ឋានប្រែប្រួលអាកាសធាតុ www.camclimate.org.kh
- ◊ ផ្តល់ជំនួយថវិកាដល់គម្រោងរបស់ស្ថាប័នរដ្ឋ និងអង្គការមិនមែនរដ្ឋាភិបាលចំនួន១៩ ដែលស្របតាមអាទិភាពប្រែប្រួលអាកាសធាតុជាតិ
- ◊ បានកំណត់ និងអនុវត្តជម្រើសបន្សាំនានានៅតំបន់ឆ្នេរ
- ◊ បានរៀបចំវេទិកាជាតិលើកទី២ និងទី៣ ស្តីពីការប្រែប្រួលអាកាសធាតុ៕

## ផ្នែកសំខាន់ៗរបស់ CCCA

### ផ្នែកទី១៖ ការរៀបចំ និងពង្រឹងគោលនយោបាយប្រែប្រួលអាកាសធាតុ

បង្កើនសមត្ថភាព ដើម្បីសម្របសម្រួលការរៀបចំគោលនយោបាយ អភិវឌ្ឍសមត្ថភាព ផ្សព្វផ្សាយ/តស៊ូមតិ និងពិនិត្យតាមដានការអនុវត្តយុទ្ធសាស្ត្រ គោលនយោបាយ និងផែនការជាតិស្តីពីការប្រែប្រួលអាកាសធាតុ។

### ផ្នែកទី២៖ ការគ្រប់គ្រងចំណេះដឹងប្រែប្រួលអាកាសធាតុ

ធ្វើឱ្យប្រសើរឡើងនូវលទ្ធភាពទទួលបានព័ត៌មានថ្មីៗ អំពីការប្រែប្រួលអាកាសធាតុ ចំណេះដឹង និងឱកាសក្នុងការរៀនសូត្រនៅគ្រប់លំដាប់ថ្នាក់។

### ផ្នែកទី៣៖ ការគ្រប់គ្រងមូលនិធិ

ពង្រឹងសមត្ថភាព គ.ជ.គ.ប.អ. ដើម្បីកៀរគរ និងចាត់ចែងមូលនិធិប្រែប្រួលអាកាសធាតុឱ្យមានប្រសិទ្ធិភាព និងដើម្បីត្រៀមខ្លួនសម្រាប់គ្រប់គ្រងមូលនិធិប្រែប្រួលអាកាសធាតុថ្នាក់ជាតិ។



ការរៀបចំសួនបន្លែតាមផ្ទះជាវិធានការបន្សាំក្នុងសហគមន៍ជនបទ

### ផ្នែកទី៤៖ ការបង្កើនសមត្ថភាពបន្សាំនៅតំបន់ឆ្នេរ

បង្កើនភាពធន់នឹងការប្រែប្រួលអាកាសធាតុរបស់សហគមន៍តំបន់ឆ្នេរ និងប្រព័ន្ធអេកូឡូស៊ី តាមរយៈការរៀបចំផែនការបន្សាំ ការធ្វើអន្តរាគមន៍នៅថ្នាក់មូលដ្ឋាន និងផ្តល់បទពិសោធន៍ជាក់ស្តែងក្នុងការកសាងផែនការបន្សាំសម្រាប់ គ.ជ.គ.ប.អ.។

### ផ្នែកទី៥៖ ការអនុវត្តគម្រោងមូលនិធិ

ពង្រឹងសមត្ថភាពស្ថាប័នរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិល ដើម្បីបង្កើត និងអនុវត្តកិច្ចផ្តួចផ្តើមដាច់ដោយឡែកពីគ្នា ឬក្នុងភាពជាដៃគូ ដើម្បីឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ ស្របនឹងអាទិភាពប្រែប្រួលអាកាសធាតុជាតិ តាមរយៈការទទួលបានធនធានហិរញ្ញវត្ថុ និងបច្ចេកទេសថ្មីៗ។

(បោះពុម្ពលើកទី១ ខែមករា ឆ្នាំ២០១៤)

**គណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ**

**ក្រសួងបរិស្ថាន**

**នាយកដ្ឋានប្រែប្រួលអាកាសធាតុ**

# កម្មវិធីសម្ព័ន្ធភាពប្រែប្រួលអាកាសធាតុកម្ពុជា (CCCA)

Implemented by: Ministry of Environment

Supported by: European Union; UNDP (Empowered lives. Resilient nations.); Danida; SWEDEN

ព័ត៌មានសម្រាប់ទំនាក់ទំនង៖

ក្រសួងបរិស្ថាន

នាយកដ្ឋានប្រែប្រួលអាកាសធាតុ

កម្មវិធីសម្ព័ន្ធភាពប្រែប្រួលអាកាសធាតុកម្ពុជា

អគារលេខ ៤៨ វុក្ខវិថីព្រះសីហនុ រាជធានីភ្នំពេញ

ទូរស័ព្ទ/ទូរសារ៖ (៨៥៥-២៣) ២១៨ ៣៧០

អ៊ីម៉ែល៖ admin@camclimate.org.kh

គេហទំព័រ www.camclimate.org.kh

## សាវតា




សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាបានអញ្ជើញចូលរួមជាអធិបតីដ៏ខ្ពង់ខ្ពស់ក្នុងពិធីបើកវេទិកាជាតិលើកទី៣ ស្តីពីការប្រែប្រួលអាកាសធាតុ ឆ្នាំ២០១៣

កម្ពុជាជាប្រទេសអភិវឌ្ឍតិចតួច និងមានសមត្ថភាពបន្សាំទាប ពោលគឺងាយរងគ្រោះបំផុតពីការប្រែប្រួលអាកាសធាតុ។ នៅក្នុងរយៈពេល ២០ឆ្នាំ (១៩៨៧-២០០៧) កម្ពុជាបានរងគ្រោះដោយទឹកជំនន់ធ្ងន់ធ្ងរចំនួន១២ លើកដែលបានសម្លាប់មនុស្ស ១.១២៥នាក់ និងបង្កការខូចខាតមានតម្លៃជាទឹកប្រាក់ ៣២៧លានដុល្លារ។ លើសពីនេះគ្រោះរាំងស្ងួត ៥លើក បានកើតឡើងក្នុងតំបន់នានានៃផ្ទៃប្រទេស បានប៉ះពាល់ដល់ប្រជាជន៦,៥លាននាក់ ដោយខូចខាតជាទឹកប្រាក់សរុប ១៣៨លានដុល្លារ (SNC, 2012)។ ព្យុះកេតសាណានៅឆ្នាំ២០០៩ បានសម្លាប់ប្រជាជនចំនួន៤៣នាក់ និងបង្កការខូចខាតជាទឹកប្រាក់១៣២លានដុល្លារ (NCDM, 2010)។ នៅឆ្នាំ២០១១ គ្រោះទឹកជំនន់បានសម្លាប់ប្រជាជន២៥០នាក់ និងបង្កការខូចខាតជាទឹកប្រាក់៥២០លានដុល្លារ (NCDM, 2011)។ ជំនន់ទឹកភ្លៀង និងទន្លេមេគង្គឆ្នាំ២០១៣បណ្តាលឱ្យមានមនុស្សស្លាប់១៦៨នាក់ និងប៉ះពាល់ដល់ការរស់នៅរបស់ពលរដ្ឋសរុបប្រមាណ ១,៨លាននាក់ (NCDM, 2013)។



ភាពរាំងស្ងួត បានធ្វើឱ្យកសិករបង្ខំចិត្តច្រូតស្រូវមកធ្វើជាចំណីសត្វ

## ការឆ្លើយតបរបស់ស្ថាប័នទៅនឹងការប្រែប្រួលអាកាសធាតុ

រាជរដ្ឋាភិបាលកម្ពុជា បានប្តេជ្ញាចិត្តទាំងនៅថ្នាក់ជាតិ និងអន្តរជាតិក្នុងការដោះស្រាយបញ្ហាប្រឈមនៃការប្រែប្រួលអាកាសធាតុ។ រាជរដ្ឋាភិបាលបានផ្តល់សច្ចាប័នដល់អនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ (UNFCCC) នៅឆ្នាំ១៩៩៥ និងពិធីសារក្យូតូនៅឆ្នាំ២០០២។

## គណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ (គ.ជ.គ.ប.អ.)

រាជរដ្ឋាភិបាល បានបង្កើត គ.ជ.គ.ប.អ. ដែលមានអាណត្តិសម្របសម្រួលកិច្ចការប្រែប្រួលអាកាសធាតុនៅថ្នាក់ជាតិ និងមានក្រសួងស្ថាប័នសំខាន់ៗចំនួន ២០ ជាសមាជិក។ គ.ជ.គ.ប.អ. មានតួនាទីជាអង្គភាពកសាងគោលនយោបាយប្រែប្រួលអាកាសធាតុ ដោយមានសម្តេចនាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ជាប្រធានកិត្តិយស និងរដ្ឋមន្ត្រីក្រសួងបរិស្ថាន ជាប្រធាន។

## ក្រសួងបរិស្ថាន

ក្រសួងបរិស្ថាន គឺជាស្ថាប័នបង្គោលនៃអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ ក្រុមការងារអន្តររដ្ឋាភិបាលស្តីពីការប្រែប្រួលអាកាសធាតុ (IPCC) និងជាស្ថាប័នជាតិទទួលបន្ទុកយន្តការអភិវឌ្ឍន៍ស្អាត (CDM)។

## នាយកដ្ឋានប្រែប្រួលអាកាសធាតុ

នាយកដ្ឋានប្រែប្រួលអាកាសធាតុ ត្រូវបានបង្កើតឡើងដោយក្រសួងបរិស្ថានក្នុងឆ្នាំ២០០៩ ដែលមានតួនាទីជាលេខាធិការដ្ឋាននៃ គ.ជ.គ.ប.អ. ដោយមានភារៈទទួលខុសត្រូវសម្របសម្រួលការរៀបចំគោលនយោបាយ និងកម្មវិធីនានា ដែលចាំបាច់សម្រាប់ឆ្លើយតបទៅនឹងផលប៉ះពាល់អវិជ្ជមាននៃការប្រែប្រួលអាកាសធាតុ។ នាយកដ្ឋាន ក៏មាននាទីកៀរគរធនធាន និងសម្របសម្រួលការអនុវត្តវិធានការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុផងដែរ តាមរយៈមូលនិធិពហុភាគីនានាដូចជា មូលនិធិប្រទេសអភិវឌ្ឍតិចតួច (LDCF) មូលនិធិបរិស្ថានពិភពលោក (GEF) មូលនិធិបន្សាំ កម្មវិធីសម្ព័ន្ធភាពប្រែប្រួលអាកាសធាតុកម្ពុជា (CCCA) កម្មវិធីយុទ្ធសាស្ត្រសម្រាប់ភាពធន់នឹងអាកាសធាតុ (SPCR) ។ល។

## សាវតារបស់ CCCA

សម្ព័ន្ធភាពប្រែប្រួលអាកាសធាតុកម្ពុជា (CCCA) គឺជាកម្មវិធីទូលំទូលាយបែបច្នៃប្រឌិតថ្មីមួយ សម្រាប់ឆ្លើយតបនឹងបញ្ហាប្រែប្រួលអាកាសធាតុនៅកម្ពុជា។ កម្មវិធីនេះ ជាកិច្ចផ្តួចផ្តើមពហុភាគីដែលទទួលមូលនិធិពីសហភាពអឺរ៉ុប (EU) ទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិនៃប្រទេសស៊ុយអែដ (Sida) ទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិនៃប្រទេសដាណឺម៉ាក (Danida) និងកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិប្រចាំនៅកម្ពុជា (UNDP)។ កិច្ចផ្តួចផ្តើមនេះស្ថិតនៅក្រោមការដឹកនាំនៃ គ.ជ.គ.ប.អ. ដែលជាស្ថាប័នទទួលបន្ទុករៀបចំ និងអនុវត្តគោលនយោបាយ ផែនការសំដៅឆ្លើយតបទៅនឹងបញ្ហាប្រែប្រួលអាកាសធាតុ ។




## គោលការណ៍ជាមូលដ្ឋានរបស់ CCCA

+ ការប្រែប្រួលអាកាសធាតុ គឺជាអាទិភាពខ្ពស់របស់រាជរដ្ឋាភិបាល និងសង្គមស៊ីវិល
+ ការប្រែប្រួលអាកាសធាតុទាក់ទងទៅនឹងជីវភាព និងបរិញ្ញើមជីវិតរបស់ប្រជាជន។ ចាំបាច់ត្រូវមានកិច្ចប្រឹងប្រែងពិសេសដើម្បីបញ្ចូលបញ្ហារបស់ស្ត្រី និងយុវជនទៅក្នុងដំណើរការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ ។
+ ការបន្សាំ និងការកាត់បន្ថយត្រូវបានដោះស្រាយក្នុងបរិបទនៃការអភិវឌ្ឍធំទូលាយ និងត្រូវផ្សារភ្ជាប់ជាមួយយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រ។